ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.....១៩៤០.......អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ២០១៣

## សេចក្តីជូនដំណឹង

*ស្តីពី*

### ការពន្យារពេលបង់ពន្ធលើអចលនទ្រព្យជាលើកទី២ សម្រាប់ឆ្នាំ២០១៣

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ មេត្តាជ្រាបថា ក្នុងអំឡុងពេលជិតបញ្ចប់ការប្រមូលពន្ធលើអចលនទ្រព្យក្នុងអំឡុងការពន្យារពេលកន្លងមក ឃើញថានៅមានម្ចាស់អចលនទ្រព្យជាច្រើននៅបាននឹងកំពុងមមាញឹកមកប្រកាសបង់ពន្ធនៅតាមបណ្តាសាខាពន្ធដារខេត្ត-ខណ្ឌ ជាហេតុធ្វើឱ្យការផ្តល់សេវាជូនអ្នកជាប់ពន្ធមិនបានទាន់ពេលវេលា ។

ដូចនេះ អគ្គនាយកដ្ឋានពន្ធដារសម្រេចពន្យារពេលប្រមូលពន្ធលើអចលនទ្រព្យបន្តទៀត រហូតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

ដើម្បីផ្តល់លទ្ធភាពកាន់តែងាយស្រួលដល់ម្ចាស់អចលនទ្រព្យ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំចាត់ចែងផ្តល់សេវាប្រមូលពន្ធនៅថ្ងៃសៅរ៍-អាទិត្យ បន្ថែមទៀត ។

អគ្គនាយកដ្ឋានពន្ធដារ មានក្តីសង្ឃឹមយ៉ាងមុតមាំថា នៅក្នុងអំឡុងពេលពន្យារនេះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក-លោកស្រី ដែលជាម្ចាស់អចលនទ្រព្យទាំងអស់ នឹងរួសរាន់មកប្រកាសបង់ពន្ធបានទាន់ពេលវេលា និងចប់សព្វគ្រប់ត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៣ ដែលជាការពន្យារពេលចុងក្រោយសម្រាប់ឆ្នាំ២០១៣ នេះ ។

ប្រតិភូរាជរដ្ឋាភិបាល
ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

អគ្គនាយកដ្ឋាន ពន្ធដារ

គង់ វិបុល

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ:(៨៥៥) ២៣ ៨៨៦ ៧០៨/ទូរសារ:(៨៥៥) ២៣ ៨៨៦ ៧០០
Corner Russian Federation & Mao Tsetong Blvd. Toek Laak 1, Toul Kauk, Phnom Penh Phone: (855) 23 886 708/ Fax: (885) 23 886 700